# មិនឱ្យអ្នកទោសណាម្នាក់ចាកចេញបានឡើយបន្ទាប់ពីបានមកដល់ និងកម្ទេចគ្មានសល់បន្ទាប់ពីបាននាំខ្លួនចេញទៅ

*ដោយ ស្តេនសឺ ទ្រាយដឺ*

*ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

*នាព្រឹកនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ីលឃី ស្តូតហ្វឺនស្កី បានចាប់ផ្តើមដំណើរការនីតិវិធីដោយអះអាងថា រយៈពេលសែសិបនាទីដែលកំណត់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរសាក្សីមានរយៈពេលគ្រប់គ្រាន់ទេ ។ លោកស្រីបានស្នើអង្គជំនុំជម្រះសាលាដំបូងផ្តល់រយៈពេលម្ភៃនាទីបន្ថែមទៀតដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានជំទាស់នឹងសំណើនេះ ហើយប្រកាន់យកថេរវេលាដែលបានកំណត់កាលពីមុន ។ ប្រធានចៅក្រមបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែប្រើប្រាស់រយៈពេលសែសិបនាទីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ហើយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវតែចៀសវាងការសួរនូវសំណួរដដែលៗ ឬសំណួរមិនសំខាន់ ដែលធ្វើឲ្យខាតបង់ពេលវេលា ។ លោកប្រធានចៅក្រម និល ណុន បានបន្តដំណើរការនីតិវិធីដោយសួរសំណួរទៅកាន់ សួស ធី អតីតកម្មាភិបាលថ្នាក់កណ្តាលដែលបំរើការជាបុគ្គលិកទូទៅនៅក្រោមបង្គាប់របស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ សួស ធី បានចាប់ផ្តើមធ្វើសក្ខីកម្មកាលពីថ្ងៃទី២៧ ខែកក្កដា ។ ជាក់ស្តែង សួស ធី មានតួនាទីរក្សាបញ្ជីឈ្មោះអ្នកទោសដែលត្រូវបាននាំចូលនិងនាំចេញពីមន្ទីរស-២១ ។*

## *ដំណើរប្រតិបត្តិការប្រចាំថ្ងៃនៅមន្ទីរស -២១ មិនឲ្យអ្នកទោសណាម្នាក់ចាកចេញបានឡើយបន្ទាប់ពីបានមកដល់ ហើយកម្ទេចគ្មានសល់បន្ទាប់ពីបាននាំខ្លួនចេញទៅ*

*ការសួរសំណួរទៅកាន់ សួស ធី ដោយលោកប្រធានចៅក្រម ចៅក្រម ខាតរ៉ាយថ៍ និងចៅក្រម ឡាវើន៍ បានផ្តល់នូវព័ត៌មានជាច្រើនទាក់ទិននឹងដំណើរការប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរស-២១ បើទោះបីជា សួស ធី បានអះអាងថា គាត់បានដឹងពីដំណើរការរបស់មន្ទីរស-២១តិចតួចដោយសារតែជាទូទៅគាត់យកចិត្តទុកដាក់តែពីកិច្ចការរបស់គាត់ក៏ដោយ ។ ស្តីពីអ្នកទោសដែលបានមកដល់មន្ទីរស-២១វិញ សួស ធី បានរៀបរាប់ថា ចំនួននិងការមកដល់របស់អ្នកទោស គឺមានលក្ខណៈខុសគ្នាជា*

ប្រចាំ ។ យ៉ាងណាមិញ មន្ទីរស-២១មិនដែលអនុញ្ញាតឲ្យអ្នកទោសណាម្នាក់ចាកចេញទៅវិញបានឡើយ ។ បន្ទប់ឃុំឃាំងនៅមន្ទីរស-២១តែងតែអាចសាងសង់បានជាបន្ទុបន្ទាប់សម្រាប់ឃុំអ្នកទោស ។ ក្រោយពីការមករបស់អ្នកទោស បុគ្គលិកមន្ទីរស-២១ដែលឋិតនៅក្នុងសម្លៀកបំពាក់ពណ៌ខ្មៅបាននាំគ្នាដោះសម្លៀកបំពាក់អ្នកទោសចេញទុកតែខោក្នុងតែប៉ុណ្ណោះ ។ សួស ធី បាននិយាយថា គាត់មិនបានទទួលឯកសារស្តីពីព័ត៌មានរបស់អ្នកទោសដែលបានមកដល់មន្ទីរស-២១ដោយផ្ទាល់នោះទេ ប៉ុន្តែគាត់បានទទួលឯកសារទាំងនោះពីថ្នាក់លើរបស់គាត់គឺសមមិត្ត ហ៊ិ ។

សម្រាប់អ្នកទោសដែលត្រូវនាំចេញ ក្រោយពី សួស ធី បានទទួលបញ្ជីឈ្មោះអ្នកទោសពីថ្នាក់លើរបស់គាត់ ឆ្មាំយាមគុកនឹងនាំអ្នកទោសទាំងនោះទៅកាន់ច្រកចេញមន្ទីរស-២១ ។ នៅទីនោះ សួស ធី នឹងត្រួតពិនិត្យឈ្មោះអ្នកទោសម្តងទៀតក្នុងរយៈពេលប្រមាណមួយម៉ោង បន្ទាប់មកនាំអ្នកទោសដាក់ក្នុងរថយន្តមួយនៅប្រហែលម៉ោងបួនល្ងាចដើម្បីយកទៅ«កម្ទេច» នៅវាលពិឃាតបឹងជើងឯក ។ កូនក្មេងមិនត្រូវបាននាំទៅសម្លាប់ជាមួយនឹងអ្នកទោសទាំងនោះទេ ។ សួស ធី មិនបានដឹងពីពេលវេលានិងទីកន្លែងដែលសម្លាប់កូនក្មេងទាំងនោះឡើយ ។ ប៉ុន្តែ គាត់គ្រាន់តែដឹងថា កូនក្មេងទាំងនោះបានមកដល់មន្ទីរស-២១ដោយគ្មានការកត់ត្រាជាឯកសារទុកទេ ។ ខណៈពេលដែលត្រូវបានសួរពីចំនួនមនុស្សដែលត្រូវបានសម្លាប់នៅវាលពិឃាតជើងឯក សួស ធី មិនហ៊ានធ្វើការប៉ាន់ស្មានឡើយ ។ គាត់គ្រាន់តែអះអាងថា គាត់បានធ្វើការ«រយៈពេលម្ភៃបួនម៉ោងក្នុងមួយថ្ងៃ» ហើយម្យ៉ាងទៀតបន្ទុកការងារទាំងនោះបានធ្វើឲ្យគាត់មិនអាចសន្និដ្ឋានពីចំនួនអ្នកទោសដែលស្លាប់ក្នុងមួយឆ្នាំ ឬមួយខែបានឡើយ បើទោះបីជាគាត់ជាអ្នកពិនិត្យបញ្ជីឈ្មោះអ្នកទោសដែលត្រូវសម្លាប់ក៏ដោយ ។

សួស ធី បានអះអាងថា បុគ្គលិកមន្ទីរស-២១ទាំងអស់«រស់នៅក្នុងភាពងងឹត» ។ ដោយសារតែហេតុផលនេះហើយ បានជាបុគ្គលិកមន្ទីរស-២១ទាំងអស់មិនដឹងជាមុនថា កងទ័ពវៀតណាមបានមកដល់ទីក្រុងភ្នំពេញ នៅដើមខែមករា ឆ្នាំ១៩៧៩ ។ ម្យ៉ាងវិញទៀត បុគ្គលិកទាំងអស់ក៏មិនបានរៀបចំគម្រោងដើម្បីបំផ្លាញឯកសារទាំងនោះឲ្យទាន់ពេលវេលាដែរ ។ ខណៈពេលដែលត្រូវសួរពីចំនួនអ្នកទោសដែលបានចាកចេញពីមន្ទីរស-២១កាលពីថ្ងៃទី៦ ឬ៧ ខែមករា ឆ្នាំ១៩៧៩ សួស ធី បាននិយាយថា អ្នកទោសទាំងអស់ត្រូវបានកម្ទេចចោលទាំងអស់លើកលែងតែអ្នកទោសពិសេស ឬអ្នកទោសដែលជាបុគ្គលិករបស់មន្ទីរស-២១ ។ ប៉ុន្តែ សួស ធី បានបន្ថែមទៀតថា គាត់មិនបានដឹងពីការសម្រេចចិត្តសម្រាប់អ្នកទោសទាំងនោះទេ ។ សួស ធី បានធ្វើការឆ្លើយតបស្រដៀងគ្នានៅពេលដែលត្រូវបានសួរពី

សភាពអ្នកទោសនៅមន្ទីរស-២១ ។ គាត់បាននិយាយទាំងមិនយកចិត្តដាក់ថា គ្រូពេទ្យគឺជាអ្នកមានតួនាទីសិក្សាពីសុខភាពរបស់អ្នកទោស ហើយរឿងនេះមិនជាប់ពាក់ព័ន្ធជាមួយនឹងការងាររបស់គាត់ទេ ពីព្រោះគាត់យកចិត្តទុកដាក់តែពីការងាររបស់គាត់ប៉ុណ្ណោះ ។ បើទោះបីជានៅពេលដែល សួស ធី ធ្វើការត្រួតពិនិត្យឈ្មោះអ្នកទោសដែលត្រូវបានដាក់ខ្នោះនិងចងភ្នែក នៅប្រកចេញមន្ទីរស-២១ក៏ដោយក៏គាត់នៅតែនិយាយថា គាត់មិនបានកត់សម្គាល់សភាពអ្នកទោសទាំងនោះទេ គាត់គ្រាន់តែបានឃើញថា អ្នកទោសទាំងនោះមានសភាព«ទន់ខ្សោយ»ប៉ុណ្ណោះ ។ ដោយមិនបានផ្តោតលើសភាពអ្នកទោស សួស ធី គ្រាន់តែរង់ចាំស្តាប់ការឆ្លើយតបរបស់អ្នកទោសនៅពេលដែលគាត់ហៅឈ្មោះអ្នកទោសទាំងនោះ ។ គាត់បានបន្ថែមទៀតថា គ្មានអ្នកទោសណាម្នាក់ដែលមានសភាពឈឺធ្ងន់ធ្ងរខ្លាំងដល់ថ្នាក់មិនអាចឆ្លើយតបនឹងការហៅឈ្មោះឡើយ ។

សួស ធី បាននិយាយថា ឌុច មានសិទ្ធិដើរត្រួតពិនិត្យមនុស្សទាំងអស់ដែលមានវត្តមាននៅក្នុងនិងក្រៅមន្ទីរស-២១ ។ ការិយាល័យសហព្រះរាជអាជ្ញាបានរកឃើញព័ត៌មានបន្ថែមទាក់ទិននឹងសិទ្ធិអំណាចនេះ ដែលទាញបាននូវព័ត៌មានស្តីពីការបូមឈាមអ្នកទោស ។ សួស ធី បាននិយាយថា ដំបូងគ្រូពេទ្យនឹងធ្វើការស្នើសុំទៅសមមិត្ត ហ៊ំ ។ បន្ទាប់មក ហ៊ំ នឹងសុំការអនុញ្ញាតពី ឌុច ។ លុះត្រាតែមានការអនុញ្ញាតពី ឌុច ទើបគ្រូពេទ្យអាចបូមឈាមអ្នកទោសបាន ។ ជាមួយគ្នានេះ សួស ធី បានរៀបរាប់ថា ជួនកាល ឌុច បានទៅត្រួតពិនិត្យរោងជាងរបស់មន្ទីរស-២១ដែលជាផ្ទះរបស់ជាងគំនូរ និងជាងចម្លាក់ ។ មានម្តងនោះ ឌុច ក៏បានមកត្រួតពិនិត្យបុគ្គលិកមន្ទីរស-២១ដល់ការិយាល័យតែម្តង ។

## សក្ខីកម្មដែលមានលក្ខណៈខុសគ្នា និងការសួរសំណួរជាផ្នែក

សហព្រះរាជអាជ្ញាបានចំណាយពេលពាក់កណ្តាលព្រឹកនេះ ដោយព្យាយាមទាញយកការឆ្លើយតបរបស់ សួស ធី ដែលមានលក្ខណៈត្រូវគ្នាជាមួយនឹងព័ត៌មានដែលទទួលបានពីការិយាល័យសហចៅក្រមស៊ើបអង្កេត ។ សួស ធី មិនបានជំទាស់ ឬយល់ស្របជាមួយនឹងព័ត៌មានភាគច្រើនដែលទទួលបានពីសហចៅក្រមស៊ើបអង្កេតទេ ដោយផ្ទុយទៅវិញគាត់បានឆ្លើយតបដោយស្រពិចស្រពិលថា គាត់មិនមានតួនាទីដឹងរឿងទាំងអស់នេះទេ ។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួនក្រុមបានអនុវត្តវិធីសាស្ត្រប្រហាក់ប្រហែលគ្នាដោយព្យាយាមទាញយកនាំការយល់ស្រប ឬជំទាស់នឹងព័ត៌មានដែលទទួលបានពីសហចៅក្រមស៊ើបអង្កេតដែរ ។ គួរឲ្យកត់សម្គាល់ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បានបោះបង់ចោលវិធីសាស្ត្រសួរសំណួរកាលពីមុនរបស់ខ្លួន ដោយធ្វើការសួរសំណួរទៅកាន់សាក្សីរៀងៗខ្លួនវិញ ។ ជាលទ្ធផល ការសួរសំណួរបែបនេះបាននាំឲ្យមានការសួរសំណួរជាផ្នែកក្នុងរយៈពេលសែសិបនាទីទៅកាន់សាក្សីតែមួយដែលបណ្ដាលឲ្យ សួស ធី ធ្វើការឆ្លើយតបដដែលៗដោយនិយាយថា គាត់មិនអាចចាំឈ្មោះនិងមុខរបស់អ្នកទាំងនោះបានទេ ។ នៅពេលដែលមេធាវី ស៊ីលឃី ស្តូតហ្វ៊ីនស្គី អស់ពេលវេលាសួរសំណួរបន្ត គាត់ក៏បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារដែលមិនទាន់បានបង្ហាញជូន និងសុំឲ្យចៅក្រមសួរសំណួរទៅកាន់សាក្សីពីឯកសារនេះ ។ បើទោះបីជាចៅក្រមមិនយល់ព្រមសួរសំណួរដែលមិនទាន់បានសួរដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទៅកាន់សាក្សីក៏ដោយ ក៏ចៅក្រមបានអនុញ្ញាតឲ្យ«ដាក់ឯកសារនេះនៅចំពោះ» អង្គជំនុំជម្រះ ។ បន្ទាប់មកទៀត ចៅក្រម ខាតរ៉ាយថ៍ បានបន្តដំណើរការនីតិវិធីដោយសួរសំណួរទាក់ទិននឹងឯកសារនោះ ប៉ុន្តែព័ត៌មានដែលទាក់ទងនឹងឯកសារនេះហាក់បីដូចជាមិនមានសារសំខាន់អ្វីឡើយ ។ តាមរយៈការសួរសំណួរសាក្សីស្ដីពីឯកសារ ដែលបានប្រគល់ឲ្យដោយដើមបណ្ដឹងរដ្ឋប្បវេណីក្រោយពីភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់អស់ពេលសួរសំណួរតទៅទៀតនោះ ចៅក្រមបានអនុញ្ញាតផ្ដល់ជូនរយៈពេលសួរសំណួរបន្ថែមឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីមួយក្រុម ដែលការធ្វើបែបនេះ ត្រូវចៅក្រមធ្លាប់បដិសេធរួចម្ដងហើយ ។ មានតែការសួរសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយទេ ដែលបានទាញយកនូវសក្ខីកម្មបន្ថែមទៀតពីសាក្សី ។ ប៉ុន្តែ ការសួរសំណួររបស់ក្រុមនេះគ្រាន់តែបានបង្ហាញថា សួស ធី បានបំរើការនៅមន្ទីរស-២១ដោយភាពភ័យខ្លាចតែប៉ុណ្ណោះ ដែលការឆ្លុះបញ្ចាំងបែបនេះ គឺជាអ្វីដែលមេធាវីការពារក្ដីរីករាយនឹងទទួលស្គាល់ ។

## «តើអ្នករីករាយនឹងបំពេញភារៈកិច្ចនៅមន្ទីរស-២១ដែរឬទេ?»

ការសួរសំណួរទៅកាន់សាក្សីដោយមេធាវីការពារក្ដី ការ សាវុត្ថ បានទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំងពីទស្សនិកជនដែលមានវត្តមាននៅក្នុងសាលសាធារណៈរបស់ អ.វ.ត.ក ។ សំណួរខ្លះមានលក្ខណៈកំប្លែងខុសប្លែកគ្នាដោយបង្កឲ្យមានជាស្នាមញញឹម និងសំណើចពីទស្សនិកជនដែលជាជនជាតិខ្មែរ និងបរទេស ។ សួស ធី បានឆ្លើយតបនឹងសំណួរដំបូងដែលសួរថា «តើអ្នកចូលចិត្តការងាររបស់អ្នកដែរឬទេ?» ដោយ សួស ធី ឆ្លើយថា គាត់មិនចូលចិត្តការងាររបស់គាត់សូម្បីតែបន្តិច ប៉ុន្តែគាត់ត្រូវតែ

បំពេញការងារទាំងនោះ ព្រោះថាបុគ្គលិកទាំងអស់មិនអាចជំទាស់នឹងបញ្ជាបានទេ។ សំណួរបន្ទាប់ទៀតបានសួរថា “ប្រសិនបើអ្នកមិនចូលចិត្តការងាររបស់អ្នក ចុះហេតុអ្វីបានជាអ្នកមិនចាកចេញពីកន្លែងនោះទៅ?” សំណួរនេះបានធ្វើឲ្យអ្នកគ្រប់គ្នាអស់សំណើច ប៉ុន្តែ សួស ធី បានឆ្លើយតបថា“តើឲ្យខ្ញុំទៅណា?”បើគ្រាន់តែខ្ញុំអវត្តមានត្រឹមតែប្រាំនាទី ខ្ញុំត្រូវបានចំណាំមុខទុកបាត់ទៅហើយនោះ។ ជាចុងក្រោយ ការ សាវុត្ថ បានបញ្ចប់ការសួរសំណួររបស់គាត់ដោយសួរថា “តើបុគ្គលិកមន្ទីរស-២១មិនចូលចិត្តការងាររបស់ខ្លួន ប៉ុន្តែមិនមានកន្លែងដែលត្រូវទៅមែនដែរឬទេ?” សួស ធី បានឆ្លើយតបថា បុគ្គលិកមន្ទីរស-២១ទាំងអស់មិនចូលចិត្តរបបខ្មែរក្រហមនេះទេ ប៉ុន្តែគ្មានអ្វីដែលអាចជួយពួកគេឲ្យរួចផុតពីរបបនេះបានឡើយ។ ដោយយល់ពីស្ថានភាពការសួរសំណួរបែបនេះរបស់ ការ សាវុត្ថ បានជួយដល់រឿងក្តីរបស់ ឌុច បានយ៉ាងល្អ។ ដោយសារតែ សួស ធី ខ្លាចថ្នាក់លើរបស់ខ្លួននៅមន្ទីរស-២១សម្លាប់ ហើយថ្នាក់លើរបស់ សួស ធី ក៏ខ្លាចថ្នាក់លើរបស់គាត់គឺ ឌុច សម្លាប់ ដូច្នេះហើយបានជាយើងអាចសន្និដ្ឋានបានថា ឌុច ខ្លាចថ្នាក់លើរបស់គាត់សម្លាប់ដែរ។ សួស ធី បាននិយាយថា រាល់សកម្មភាពទាំងអស់បានកើតឡើងដោយសារតែថ្នាក់លើជាន់ខ្ពស់បំផុតរបស់បក្ស។ មិនថាថ្នាក់លើចេញបញ្ជាអ្វីក៏ដោយ ក៏អ្នកនៅក្រោមបង្គាប់ទាំងអស់ត្រូវតែធ្វើតាមទាំងអស់។ ប្រសិនបើនរណាម្នាក់ហ៊ានមិនគោរពតាមបញ្ជាអ្នកនោះដឹងថា ទណ្ឌកម្មធ្ងន់ធ្ងរនឹងកើតមានភ្លាមមកលើរូបគេ។